**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមការងារបច្ចេកទេស
លេខ....................

## កំណត់ហេតុអង្គប្រជុំ

កាលពីថ្ងៃទីម្ភៃប្រាំពីរ ខែធ្នូ ឆ្នាំពីរពាន់ដប់បី វេលាម៉ោងប្រាំបួន និងសូន្យនាទី នៅសាលប្រជុំនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំកិច្ចប្រជុំមួយ ក្រោមអធិបតីភាព **ឯកឧត្តម សយ សុខាន់** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងជាប្រធានក្រុមការងារបច្ចេកទេស ដោយមានការចូលរួមពី សំណាក់សមាជិកក្រុមការងារបច្ចេកទេស តំណាងប្រជាពលរដ្ឋសមាគមន៍ភូមិថ្មគោល តំណាងអាជ្ញាធរដែនដីពាក់ព័ន្ធ និងតំណាងអង្គការក្រៅរដ្ឋាភិបាល (NGO) ដូចមានឈ្មោះក្នុងបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ ដើម្បីពិនិត្យ និងពិភាក្សាលើសំណើរបស់តំណាងប្រជាពលរដ្ឋ សមាគមន៍ភូមិថ្មគោល ដូចខាងក្រោម៖

1. ការកំណត់តំបន់សន្តិសុខ និងតំបន់សុវត្ថិភាពនៅជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
2. ការត្រៀមរៀបចំប្រជុំផ្សព្វផ្សាយជាសាធារណៈជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ ក្នុងតំបន់សន្តិសុខ និងតំបន់សុវត្ថិភាពនៅជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
3. បញ្ហាផ្សេងៗ

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម សយ សុខាន់** ប្រធានអង្គប្រជុំ បានស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណ ជ្រាលជ្រៅចំពោះសមាជិកអង្គប្រជុំទាំងអស់ ដែលបានមកចូលរួមកិច្ចប្រជុំនៅព្រឹកនេះ។ ម្យ៉ាងវិញទៀត ដើម្បីឱ្យអង្គប្រជុំជ្រាបកាន់តែច្បាស់ និងមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់កិច្ចពិភាក្សារកដំណោះស្រាយនោះ ឯកឧត្តមប្រធានអង្គប្រជុំ បានអនុញ្ញាតឲ្យ លោក សុខ ពុធឿន ប្រធាននាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន ធ្វើបទបង្ហាញជូនអង្គប្រជុំជ្រាបអំពីទីតាំងតំបន់សន្តិសុខ និងតំបន់សុវត្ថិភាពនៅជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

លោក សុខ ពុធឿន បានបង្ហាញថា នេះជាទីតាំងតំបន់សន្តិសុខ និងតំបន់សុវត្ថិភាព នៅជុំបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលក្រុមជំនាញបានសិក្សា និងកំណត់ប្លង់នៅលើផែនទី។ ការកំណត់ទីតាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីសន្តិសុខ និងសុវត្ថិភាពអាកាសចរស៊ីវិល និងស្តង់ដាអង្គការអាកាសចរស៊ីវិលអន្តរជាតិ ដែលមានបទដ្ឋាន៖

- តំបន់សន្តិសុខ មានតំលាត 5 ម៉ែត្រ ឃ្លាតចេញពីរបងអាកាសយានដ្ឋានបច្ចុប្បន្ន ចាប់ពីចុងផ្លូវរត់ឡើង-ចុះ ទិស 05 (ចោមចៅ) ដល់ចុងផ្លូវរត់ឡើង-ចុះទិស23 (កែងផ្លូវ 2004) ដែលមានបណ្តោយប្រវែង 5410 ម៉ែត្រ ស្មើនឹង 2,71 ហិចតា។ រីឯផ្នែកខាងមុខអាកាសយានដ្ឋាន តាមបណ្តោយផ្លូវសហព័ន្ធរុស្ស៊ី ត្រូវបានធ្វើកែ សម្រួលរួចហើយ។
- តំបន់សុវត្ថិភាព ផ្នែកខាងមុខវាលផ្លូវរត់ឡើង-ចុះទិស 05 (ចោមចៅ) នឹងធ្វើការកែសម្រួលបណ្តោយ 500 ម៉ែត្រ និងទទឹង 319 ម៉ែត ស្មើនិង 4,72 ហិចតា។ រីឯផ្នែកខាងមុខវាលផ្លូវរត់ឡើង-ចុះទិស 23 (ផ្សារពោធិចិនតុង) ត្រូវបានធ្វើការកែសម្រួលរួចហើយ។

លោក សុខ ពុធឿន បានបញ្ជាក់បន្ថែមថា អ្វីដែលក្រុមជំនាញបានរៀបចំនេះ ជាកាតព្វកិច្ចរបស់រដ្ឋជាសមាជិកនៃអង្គការ ICAO ដែលត្រូវបំពេញស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីធានាសន្តិសុខ និងសុវត្ថិភាព ដល់កិច្ចប្រតិបត្តិការអាកាសយានគ្រប់ប្រភេទនៅកម្ពុជា។ បើពុំដូច្នោះទេ អង្គការ ICAO នឹងដាក់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ចូលក្នុងបញ្ជីខ្មៅ នឹងមិនអនុញ្ញាតឱ្យអាកាសយានអន្តរជាតិគ្រប់ប្រភេទហោះហើរចូលមក កម្ពុជា ទៀតឡើយ។

លោក ជា សារិន ភ្នាក់ងារឯករាជ្យ បានបញ្ជាក់ជូនថា លោកធ្លាប់មានបទពិសោធន៍លើការងារដោះស្រាយផលប៉ះពាល់ជាច្រើនគម្រោងកន្លងមក ដូច្នេះ ដើម្បីជោគជ័យក្នុងការដោះស្រាយផលប៉ះពាល់ ត្រូវមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋរងផលប៉ះពាល់ ត្រូវមានកិច្ចសហការល្អពីសំណាក់អាជ្ញាធរមូលដ្ឋាន គ្រប់លំដាប់ថ្នាក់ ត្រូវការពេលវេលាមួយសមស្រប និងការអនុវត្តតាមដំណាក់កាលដែលរួមមាន ការវាស់វែង កំណត់ព្រំលម្អិត ការសិក្សាអំពី ផលប៉ះពាល់

ការរៀបចំផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ ការរុះរើផ្លាស់ទីតាំង និងការយកចិត្តទុកដាក់ជាពិសេស លើគ្រួសារក្រីក្រ ជនងាយរងគ្រោះ ចាស់ជរា ស្ត្រីមេម៉ាយគ្មានទីពឹង និងជនពិការ។ រាល់គ្រប់សកម្មភាពទាំងឡាយនៃដំណើរការដោះស្រាយផលប៉ះពាល់ ត្រូវមានការប្រជុំពិគ្រោះយោបល់ពី ប្រជាពលរដ្ឋរងផលប៉ះពាល់។ ចំពោះ គោលការណ៍នានា សម្រាប់ការងារដោះស្រាយផលប៉ះពាល់នេះ នឹងអនុវត្តតាមគោលការណ៍នៃអង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ហៅកាត់ថា (IFC) ដែលជាផ្នែកមួយរបស់ធនាគារពិភពលោក (World Bank)។ ជាចុងក្រោយ លោក ជា សារិន ក៏បានសំណូមពរដល់គ្រប់ប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងអស់ មេត្តាចូលរួមគ្រប់សកម្មភាព និងមានភាពអត់ធ្មត់ខ្ពស់ក្នុងដំណើរការដោះស្រាយផលប៉ះពាល់នេះ។

ក្រុមតំណាងប្រជាពលរដ្ឋសមាគមន៍ភូមិថ្មគោល បានលើកឡើងថា សុំឲ្យការដោះស្រាយត្រូវគោរពលើ គោលការណ៍ច្បាប់ជាមូលដ្ឋាន សុំឲ្យបញ្ចូលតំណាងប្រជាពលរដ្ឋរងផលប៉ះពាល់ និងតំណាងអង្គការក្រៅរដ្ឋាភិបាល (NGO) ជាសមាជិកគណៈកម្មការ និងស្នើសុំឲ្យគណៈកម្មការ ពិចារណាលើទីតាំងដីមួយកន្លែងសម្រាប់ការតាំងទីលំនៅថ្មីរបស់ពួកគាត់ និងសុំបញ្ជាក់អំពីគោលបំណងនៃការបោះបង្គោលឱ្យបានច្បាស់លាស់ផងដែរ។

តំណាងអង្គការក្រៅរដ្ឋាភិបាល (NGO) បានស្នើសុំឲ្យគណៈកម្មការ និងអជ្ញាធរដែនដី សហការជិតស្និត និងយកចិត្តទុកដាក់ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ ទាំងការចុះបោះបង្គោល ការធ្វើជំរឿន និងការកំណត់នីតិវិធី និងគោលការណ៍ដោះស្រាយផលប៉ះពាល់ជាពិសេស។ ម្យ៉ាងទៀត ជាបទពិសោធន៍ ដែលពួកគាត់ធ្លាប់ជួបប្រទះ ដូចជានៅសហគមន៍បុរីកីឡា និងសហគមន៍បឹងកក់ជាដើម ដែលការចុះធ្វើសម្រង់ស្ថិតិ និងការធ្វើជំរឿន មិនមានភាពច្បាស់លាស់ ធ្វើឱ្យអ្នកស្នាក់នៅពិតប្រាកដ មិនមានឈ្មោះក្នុងបញ្ជីជំរឿន បែរជាមានឈ្មោះអ្នកចំណូលថ្មីទៅវិញ។ តំណាងអង្គការក្រៅរដ្ឋាភិបាល (NGO) បានស្នើសុំឱ្យគណៈកម្មការ ផ្តល់របាយការណ៍វាយតម្លៃអំពីការកំណត់បទដ្ឋានបច្ចេកទេស និងរបាយការណ៍វាយតម្លៃអំពីផលប៉ះពាល់សង្គមផងដែរ។

ជាការឆ្លើយតប និងដើម្បីឱ្យអង្គប្រជុំយល់កាន់តែច្បាស់អំពីសាវតា គោលបំណង មូលហេតុ នីតិវិធី និង គោលការណ៍នៃការដោះស្រាយផលប៉ះពាល់ **ឯកឧត្តមប្រធានអង្គប្រជុំ** បានបញ្ជាក់ជូនថា៖

- សាវតា: អាកាយានដ្ឋានអន្តរជាតិភ្នំពេញ ត្រូវបានសាងសង់ និងដាក់ឱ្យដំណើរការនៅឆ្នាំ1956 លើផ្ទៃដី 387 ហិចតា និងត្រូវបានបើកឱ្យដំណើរការជាលើកទី2 នៅឆ្នាំ1979។ យោងលិខិតចុះថ្ងៃទី8 ខែកក្កដា ឆ្នាំ2009 របស់សាលារាជធានីភ្នំពេញ និងលិខិតចុះថ្ងៃទី8 ខែមករា ឆ្នាំ2010 របស់ក្រសួងមហាផ្ទៃ បានគូសបញ្ជាក់ថា មុនឆ្នាំ2005 មានប្រជាពលរដ្ឋមកតាំងទីលំនៅក្នុងតំបន់គ្រប់គ្រងសន្តិសុខ និងសុវត្ថិភាព ប្រមាណ 74 ខ្នងផ្ទះ ស្មើនឹង 104 គ្រួសារប៉ុណ្ណោះ។ ការដោះស្រាយបញ្ហាសំណង់ជុំវិញបរិវេណអាកាស យានដ្ឋានអន្តរជាតិភ្នំពេញ ត្រូវបានចាប់ផ្តើមឡើងតាំងពីឆ្នាំ២០០៥ ប៉ុន្តែរហូតមកដល់ពេលនេះ នៅពុំទាន់ដោះស្រាយបាននៅឡើយ។ នៅឆ្នាំ1995 អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក៏ត្រូវបានធ្វើការអភិវឌ្ឍន៍ និងកែសម្រួលដល់លំដាប់ថ្នាក់ 4E ស្របតាមស្តង់ដាអង្គការ ICAO ដែលអាចទទួលការចុះចត-ហោះឡើង អាកាសយានគ្រប់ប្រភេទផងដែរ ។
- គោលបំណង: ដើម្បីបង្កើនប្រសិទ្ធិភាពលើការគ្រប់គ្រងសន្តិសុខ និងសុវត្ថិភាពសម្រាប់កិច្ចប្រតិបត្តិការអាកាសយានជាតិ និងអន្តរជាតិ គ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- មូលហេតុ: ដោយកម្ពុជា ជាសមាជិកអង្គការ ICAO ដែលមានកាតព្វកិច្ចគោរពតាមអនុសញ្ញាស៊ីហ្កាកូ ឆ្នាំ1944 ស្តីពីច្បាប់អាកាសចរស៊ីវិលអន្តរជាតិ និង ផ្អែកតាមលទ្ធផលសវនកម្មរបស់អង្គការ ICAO នៅកម្ពុជា ឆ្នាំ ២០០៧ លើការងារសុវត្ថិភាព និង ឆ្នាំ ២០០៨ លើការងារសន្តិសុខ បានរកឃើញនូវចំណុចខ្វះខាតជាច្រើន ដែលតម្រូវឱ្យ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ធ្វើការកែសម្រួល ជាពិសេសការកំណត់ តំបន់សន្តិសុខ និងតំបន់សុវត្ថិភាពជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ នៅឆ្នាំ២០១២ ក្រុមការងារបច្ចេកទេសនៃបណ្តាប្រទេស ដែលត្រូវចូលរួមកិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ក៏បានចុះមកពិនិត្យនិងវាយតម្លៃលើស្ថានភាពសន្តិសុខ-សុវត្ថិភាពនិងសណ្តាប់សាធារណៈជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មុនការចុះចតអាកាសយានថ្នាក់ដឹកនាំរបស់ពួកគេ ហើយ ក្នុងពេលនោះពួកគេ ក៏បានស្នើសុំឱ្យធ្វើការកែតម្រូវជាបន្ទាន់ ស្របតាមស្តង់ដានិងបទប្បញ្ញត្តិស្តីពី សន្តិសុខ សុវត្ថិភាពអាកាសចរស៊ីវិល ផងដែរ។
- **នីតិវិធី និងគោលការណ៍:** ការដោះស្រាយផលប៉ះពាល់ ដំណើរការទៅតាម ដំណាក់កាលដូចខាងក្រោម៖

ដំណាក់កាលទី០១ ៖ ជួបប្រជុំជាមួយប្រជាពលរដ្ឋ ដើម្បីជម្រាបជូន និងផ្សព្វផ្សាយ អំពីគោលបំណង និងមូលហេតុនៃការកំណត់តំបន់សន្តិសុខ និងតំបន់សុវត្ថិភាពជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (រៀបចំដោយគណៈកម្មការ)។

ភ្ញ

ដំណាក់កាលទី០២ ៖ ចុះបោះបង្គោលកំណត់ព្រំខ័ណ្ឌស្របតាមនិយាមការ នៃតំបន់សន្តិសុខ និងតំបន់សុវត្ថិភាព លើផ្ទៃដីជាក់ស្តែង នៅជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (រៀបចំដោយក្រុមការងារបច្ចេកទេស)។

ដំណាក់កាលទី០៣ ៖ ចុះវាស់វែងលម្អិតកំណត់ព្រំប្រទល់ក្បាលដី ធ្វើជំរឿនអំពីស្ថានភាពគ្រួសារ រងផលប៉ះពាល់ និងធ្វើការសិក្សាអំពីតម្លៃដី (រៀបចំដោយភ្នាក់ងារឯករាជ្យ)។

ដំណាក់កាលទី០៤ ៖ ភ្នាក់ងារឯករាជ្យ រៀបចំបញ្ចូលទិន្នន័យ ដែលប្រមូលបាន បញ្ចូលក្នុងផែនការសកម្មភាពដោះស្រាយផលប៉ះពាល់(RAP) រួចបញ្ជូន RAP ទៅគណៈកម្មការពិនិត្យ និងកែសម្រួល។ បន្ទាប់មកគណៈកម្មការ ដាក់ RAP ជូនអង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកមួយរបស់ធនាគារពិភពលោក ពិនិត្យ និងផ្តល់ការយល់ព្រម។ ក្រោយពីមានការទទួលស្គាល់ដោយអង្គការ IFC ទើបគណៈកម្មការ នឹងចុះហត្ថលេខាលើ RAP ជាផ្លូវការ។

ដំណាក់កាលទី០៥ ៖ ជួបប្រជុំជាលើកទីពីរ ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ ដើម្បីជម្រាបជូននឹងផ្សព្វផ្សាយអំពីគោលការណ៍ និងផែនការសកម្មភាពដោះស្រាយផលប៉ះពាល់ និងបិទប្រកាសផ្សព្វផ្សាយជាសាធារណៈ នៅតាម ស្នាក់ការ ភូមិ សង្កាត់ ខ័ណ្ឌ ក្រុង និងការិយាល័យទទួលពាក្យបណ្តឹងរបស់គណៈកម្មការ (រៀបចំដោយ គណៈកម្មការ)។

ដំណាក់កាលទី០៦ ៖ លក្ខខ័ណ្ឌនៃការទូទាត់សំណង និងការចាកចេញ របស់ប្រជាពលរដ្ឋរងផលប៉ះ នឹងមានចែងលម្អិតក្នុងផែនការសកម្មភាពដោះស្រាយផលប៉ះពាល់។

ចំពោះសំណូមពររបស់ក្រុមតំណាងប្រជាពលរដ្ឋសហគមន៍ភូមិថ្មគោល ឯកឧត្តមប្រធានអង្គប្រជុំ បានគូសបញ្ជាក់យ៉ាងច្បាស់ថា រាល់ការដោះស្រាយផលប៉ះពាល់ នឹងប្រព្រឹត្តតាមគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិ។ រីឯការបោះបង្គោលកំណត់ព្រំខ័ណ្ឌ តំបន់សន្តិសុខ និងតំបន់សុវត្ថិភាព ជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មិនមែនមាន ន័យថាជាការរឹមអូសយកដីធ្លី ផ្ទះសម្បែង ឬការបណ្តេញប្រជាពលរដ្ឋចេញ ពីលំនៅដ្ឋាននោះទេ។ ការបោះបង្គោល កំណត់ព្រំខ័ណ្ឌនេះ គឺជាការកំណត់សំគាល់តំបន់សន្តិសុខ និងតំបន់សុវត្ថិភាព និងជាការសម្រួលដល់ភ្នាក់ងារឯករាជ្យ ក្នុងការចុះធ្វើសម្រង់ស្ថិតិ ជំរឿន សិក្សាតម្លៃ មុននឹងឈាន ដល់ការដោះស្រាយផលប៉ះពាល់ប៉ុណ្ណោះ។ ហើយការចាកចេញរបស់ប្រជាពលរដ្ឋពីតំបន់នេះ លុះណាមានការព្រមព្រៀងទទួលយកសំណង។ ដោយឡែក ការស្នើសុំបញ្ចូលតំណាងប្រជាពលរដ្ឋសហគមន៍ភូមិថ្មគោល និងតំណាងអង្គការក្រៅរដ្ឋាភិបាល ក្នុងគណៈកម្មការនោះ មិនអាចទទួលយកបានទេ ព្រោះវាផ្ទុយនឹងនីតិវិធីរដ្ឋបាល ។ ប៉ុន្តែ ប្រជាពលរដ្ឋរងផលប៉ះពាល់ អាចរៀបចំជាក្រុមតំណាងរបស់ពួកគេ ដើរតួនាទីជាអ្នកសម្របសម្រួល ជាមួយគណៈកម្មការ និងអាជ្ញាធរពាក់ព័ន្ធ បានគ្រប់ពេលវេលា។ គណៈកម្មការ នឹងពិចារណារលើទីតាំងមួយកន្លែងដែលស្នើសុំដោយតំណាងប្រជាពលរដ្ឋសហគមន៍ភូមិថ្មគោល សម្រាប់តាំងទីលំនៅថ្មីរបស់ពួកគាត់ ក្រោយពីការសិក្សាផលប៉ះពាល់ត្រូវបានបញ្ចប់។

ចំពោះសំណូមពររបស់អង្គការក្រៅរដ្ឋាភិបាល ឯកឧត្តមប្រធានអង្គប្រជុំ បានសង្កត់ធ្ងន់ថាគណៈកម្មការនឹងសហការយ៉ាងជិតស្និតជាមួយ ក្រុមការងារបច្ចេកទេស អាជ្ញាធរដែនដីពាក់ព័ន្ធ ភ្នាក់ងារឯករាជ្យ និងប្រជាពលរដ្ឋរងផលប៉ះពាល់ទាំងអស់ ជាពិសេសអង្គការ NGO ដែលមានបំណងចង់ចូលរួមសហការ នៅពេលចាប់ផ្តើមដំណើរការរហូតដល់ការដោះស្រាយផលប៉ះពាល់ ត្រូវបានបញ្ចប់ដោយចៀសវាងដាច់ខាត មិនឱ្យមានការកើតឡើងជាយថាហេតុនូវបញ្ហាណាមួយជាដាច់ខាត។ ក្រុមការងារបច្ចេកទេស នឹងផ្តល់របាយការណ៍វាយ តម្លៃអំពីការកំណត់បទដ្ឋានបច្ចេកទេស ជូនតាមការស្នើសុំ។ រីឯ របាយការណ៍វាយតម្លៃអំពីផលប៉ះពាល់សង្គមនិងផ្តល់ឱ្យ បានបន្ទាប់ពីការសម្រង់ស្ថិតិ ការធ្វើជំរឿន និងសិក្សាតម្លៃ បានប្រព្រឹត្តិទៅរួចរាល់។

សេចក្តីសន្និដ្ឋានរបស់អង្គប្រជុំ ៖

1- ក្រុមការងារបច្ចេកទេស ត្រូវរៀបចំរបាយការណ៍វាយតម្លៃអំពីការកំណត់បទដ្ឋានបច្ចេកទេស ឱ្យបានគ្រប់ ជ្រុងជ្រោយ ដើម្បីផ្សព្វផ្សាយជូន ប្រជាពលរដ្ឋរងផលប៉ះពាល់ អាជ្ញាធរដែនដីពាក់ព័ន្ធ និងស្ថាប័ន ពាក់ព័ន្ធ ជ្រាបជាពត៌មាន។

2- ក្រុមការងារបច្ចេកទេស ត្រូវត្រៀមលក្ខណៈសម្បត្តិ និងរៀបចំឧបករណ៍ សម្ភារៈបច្ចេកទេស ដើម្បីចុះ អនុវត្ត គម្រោង បន្ទាប់ពីមានការសម្រេចរបស់គណៈកម្មការ។

3- ក្រុមការងារបច្ចេកទេស ស្នើសុំឱ្យដាក់កំណត់ហេតុអង្គប្រជុំថ្ងៃនេះ (27 ធ្នូ 2013) ជូនអង្គប្រជុំគណៈកម្មការ ពិនិត្យ និង កែសម្រួល និងផ្តល់ការយល់ព្រមជាមូលដ្ឋាន។

4. ស្នើសុំឱ្យមានកិច្ចប្រជុំរបស់គណៈកម្មការនាពេលឆាប់ៗខាងមុខនេះ ដើម្បីពិនិត្យ និងពិភាក្សា លើការរៀបចំវិធានការ នីតិវិធី និងកាលបរិច្ឆេទជាក់លាក់ក្នុងការជួបប្រជុំ ជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់ជាលើកដំបូង។

ជាចុងបញ្ចាប់ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានស្នើសុំដោយទទូចដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ អាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ត្រូវចូលរួមសហការយ៉ាងជិតស្និតជាមួយក្រុមការងារបច្ចេកទេសដើម្បីឱ្យការបោះបង្គោលដំណើរទៅបាន។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ពីរនិងដប់ប្រាំនាទីរសៀល នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាស រីករាយស្និទ្ធស្នាលប្រកបដោយស្មារតីឯកភាព និងការទទួលខុសត្រូវខ្ពស់ ៕

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមករា ឆ្នាំ២០១៤

ប្រធានអង្គប្រជុំ
បានឃើញ និងឯកភាព

ឯកឧត្តម សយ សុខាន់
អនុរដ្ឋលេខាធិការ
នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
និងជាប្រធានក្រុមការងារបច្ចេកទេស

អ្នកធ្វើកំណត់ហេតុ

ឯកឧត្តម ប៊ុន រដ្ឋា
នាយកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

ប្រធានគណៈកម្មការអន្តរក្រសួង
បានឃើញ និងឯកភាព

ឯកឧត្តម ទេសរដ្ឋមន្ត្រី ឃឹម ណុលឡា

**<u>ចម្លងជូន</u>**:
-គណៈកម្មការអន្តរក្រសួង
-ក្រុមការងារបច្ចេកទេស
-សាលារាជធានីភ្នំពេញ
-សាលាខណ្ឌពោធិ៍សែនជ័យ
-សាលាសង្កាត់កាកាប
-សាលាសង្កាត់ចោមចៅ
-ប្រធានភូមិពាក់ព័ន្ធ
-ក្រុមហ៊ុន SCA/CAMS
-គ្រប់សមាជិកអង្គប្រជុំ
-ឯកសារ